World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧

១៧ សីហា ឆ្នាំ២០២០

របាយការណ៍គិតត្រឹមថ្ងៃទី១៧ សីហា ឆ្នាំ២០២០ ម៉ោង១០:០០នាទីព្រឹក

# ស្ថានការណ៍សង្ខេប

## សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ពេលបច្ចុប្បន្ន

- ត្រឹមថ្ងៃទី១៦ ខែសីហា ២០២០នេះ មានករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ២៧៣ ករណីដែលត្រូវបានរាយការណ៍មកអង្គការសុខភាពពិភពលោក។ នៅក្នុងចំណោមនោះ មាន២៣៨ករណី បានជាសះស្បើយ។ ចំនួន២៣៥ករណី ត្រូវបាននាំចូលមកពី ១១ប្រទេសផ្សេងគ្នា និងនាំចូលដោយប្រជាជនកម្ពុជាវិលមកពីក្រៅប្រទេសផងដែរ ហើយក្រៅពីនោះបានឆ្លងបន្តរពីអ្នកដែលនាំចូលពីក្រៅ។ នៅភ្នំពេញ អ្នកជំងឺកូវីដ-១៩ ចំនួន២៧នាក់ កំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែរាជធានីភ្នំពេញ និងម្នាក់ទៀតនៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ។ អ្នកជំងឺកូវីដ-១៩ ចំនួន០៣នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ និងអ្នកជំងឺកូវីដ-១៩ ចំនួន០៤នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ ។
- អ្នកប៉ះពាល់នឹងអ្នកជំងឺកូវីដ-១៩ចំនួន៥៧១នាក់ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កនៅភ្នំពេញ ឬក៏នៅតាមខេត្តរៀងខ្លួន និងត្រូវតាមដានជារៀងរាល់ថ្ងៃអំពីការវិវត្តន៍នៃរោគសញ្ញាណាមួយ។
- ផែនការមេថ្នាក់ជាតិស្តីអំពីជំងឺកូវីដ-១៩  មានដាក់បញ្ចូលនូវការបង្កើតគណៈកម្មាធិការពហុវិស័យថ្នាក់រាជធានី-ខេត្តនានា ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត។ ផែនការនានា ត្រូវបាននិងកំពុងបង្កើតឡើងដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក ដើម្បីពង្រឹងសមត្ថភាពថ្នាក់ស្រុក និងខេត្តជុំវិញសកម្មភាពអាទិភាពសំខាន់ៗមួយចំនួន។
- ការផ្តោតលើការពង្រឹងសមត្ថភាពនិងការត្រៀមខ្លួននៃប្រព័ន្ធសុខាភិបាលនៅតែបន្ត។ ឧបករណ៍វាស់ជីពចរ អុកស៊ីសែន (oxygen pulse oximeters) ចំនួន ១៤០ គ្រឿង ត្រូវបានដឹកជញ្ជូនមកដល់កម្ពុជាហើយ ខណៈដែលការដឹកជញ្ជូនឧបករណ៍ចម្រោះអុកស៊ីសែន (oxygen concentrators) ចំនួន ៣០០គ្រឿង និងសម្ភារបរិក្ខាការពារខ្លួន នឹងត្រូវដឹកជញ្ជូនមកដល់នៅចុងខែសីហា ឆ្នាំ២០២០នេះ។
- ក្រសួងអប់រំយុវជននិងកីឡា បានចេញផ្សាយគោលការណ៍ណែនាំ និងស្តង់ដារប្រតិបិត្តសម្រាប់ការបើកសាលារៀនឡើងវិញក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចកែប្រែដំណាក់កាលទីពីរនៃការបើកសាលាឡើងវិញ ដែលនេះមានន័យថាការបើកសាលារៀនឡើងវិញនៅទូទាំងប្រទេសសម្រាប់សិស្សថ្នាក់ទី៩ និងថ្នាក់ទី១២ នឹងត្រូវធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០២០។

# ព្រឹត្តិការណ៍ និងអាទិភាពដែលនឹងមកដល់

- ក្រុមឆ្លើយតបបន្ទាន់នៅថ្នាក់ខេត្ត នឹងទទួលបានការបណ្តុះបណ្តាលដើម្បីពង្រឹងសម្ថភាពក្នុងការតាមរកអ្នកប៉ះពាល់ និងតាមដានជំងឺ។ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល នឹងដឹកនាំវគ្គបណ្តុះបណ្តាលគ្រូបង្គោលដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការ ដៃគូដែលរួមមានអង្គការសុខភាពពិភពលោក។ ការបណ្តុះបណ្តាលនេះ នឹងត្រូវរៀបចំក្រុមឆ្លើយតបបន្ទាន់នៅថ្នាក់ស្រុក និងតាមមណ្ឌលសុខភាព។
- ក្រសួងសុខាភិបាលបានចាប់ផ្តើមធ្វើការវាយតម្លៃដំណាក់កាលចម្លងប្រចាំសប្តាហ៍ថ្នាក់ជាតិ ជាមួយនឹងការតាមដានជំងឺដោយប្រើពហុប្រភពព័ត៌មានហើយនិងផែនការធ្វើការវាយតម្លៃសម្រាប់រាជធានី-ខេត្តនានា។
- ខេត្តស្វាយរៀង ត្រូវបានជ្រើសរើសមួយដើម្បីសាកល្បងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩តាមសហគមន៍។
- ក្រសួងសុខាភិបាល គ្រោងពង្រឹងសមត្ថភាព និងផ្ទេររំលែកការងារធ្វើតេស្តពិសោធន៍រកករណីកូវីដ-១៩ ទៅដល់មន្ទីរពិសោធន៍ក្នុងខេត្តចំនួនបី គឺខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ គម្រោងស្នើសុំមូលនិធិលំម្អិតសម្រាប់ការពង្រីកសមត្ថភាពធ្វើរោគវិនិច្ឆ័យម៉ូលេគុលប្រកបដោយនិរន្តរភាពនៅកម្ពុជា ត្រូវបានរៀបចំរួចហើយ។ ការធ្វើតេសនៅមន្ទីពិសោធន៍ថ្មីក្នុងខេត្តសៀមរាបនេះ នឹងចាប់ផ្តើមនៅខែសីហានេះ ហើយសកលវិទ្យាល័យវិទ្យាសាស្រ្តសុខាភិបាល ត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមធ្វើតេស្តសម្រាប់រយៈពេលសាកល្បងចំនួនមួយខែ។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងបញ្ចប់កំណែលើកទី៣នៃគោលការណែនាំគ្លីនិក។ គោលការណ៍ណែនាំនេះ មានរួមបញ្ចូលមាតិកាស្តីពីការគ្រប់គ្រងករណីជំងឺធ្ងន់ធ្ងរ ឧបករណ៍ចម្រោះអុកស៊ីសែន និងនីតិវិធីសម្រាប់តាមដានវីរុសកូវីដ-១៩  (SARS-CoV-2) លក្ខណៈវិច្ឆ័យសម្រាប់ការអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ ការប្រើប្រាស់ឱសថ និងការគ្រប់គ្រងក្រោយពេលចេញពីមន្ទីរពេទ្យ។ សេចក្តីសង្ខេបបច្ចេកទេសមួយស្តីពីជំងឺកូវីដ-១៩ សុខភាពបន្តពូជ មាតា និងទារក ដែលមជ្ឈមណ្ឌលសុខភាពមាតា និងទារកដឹកនាំរៀបចំ នឹងត្រូវធ្វើរួចរាល់ ដើម្បីបំពេញបន្ថែមឲ្យគោលការណ៍ណែនាំគ្លីនិក។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩  ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- កម្មវិធីជាតិផ្តល់ថ្នាំបង្ការ កំពុងរៀបចំផែនការជាតិដាក់ពង្រាយ និងផ្តល់ថ្នាំបង្ការសម្រាប់ជំងឺកូវីដ-១៩ (COVID-19 National Deployment and Vaccination Plan, NDVP)។
- រាជរដ្ឋាភិបាលកំពុងបន្តវាយតម្លៃពីការកែតម្រូវអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (Non-Pharmaceutical Intervention) ដោយប្រើវិធីសាស្ត្រជាជំហានៗ និងពិនិត្យទៅលើប្រសិទ្ធភាព ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម ក៏ដូចជាពិនិត្យទៅលើថាតើសធារណៈជនទទួលយកបាននូវវិធានការណ៍នីមួយៗដែលបានដាក់ចេញដែរឬទេ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការតាមដានជំងឺដើម្បីធ្វើការសម្រេចចិត្តឲ្យបានត្រឹមត្រូវ។
- ក្រសួងសុខាភិបាលនឹងចូលរួមកិច្ចប្រជុំក្រុមផ្តល់ប្រឹក្សាបច្ចេកទេសអំពីការគ្របដណ្តប់សុខភាពជាសកល (UHC TAG) រៀបចំដោយអង្គការសុខភាពពិភពលោកថ្នាក់តំបន់ប៉ាស៊ីហ្វិកភាគខាងលិចនៅសប្តាហ៍ក្រោយ។ កិច្ចប្រជុំនេះ នឹងផ្តោតទៅលើផលប៉ះពាល់នៃជំងឺកូវីដ-១៩ទៅលើវឌ្ឍនភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល។

# ការវាយតម្លៃនៃអត្រាឆ្លងជំងឺថ្នាក់ជាតិ

**១. នាំចូល-** គិតត្រឹមថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០នេះ ករណីវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ២៣៥ករណី ឬ ៨៦ភាគរយនៃចំនួនករណីសរុប២៧៣ ជាករណីនាំចូលពីបរទេស ហើយសល់ពីហ្នឹងជាករណីឆ្លងក្នុងប្រទេសកម្ពុជា និងមានការពាក់ព័ន្ធនឹងករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍។ ចាប់តាំងពីថ្ងៃទី១១ ខែមេសាមក មានករណីវិជ្ជមានវីរុសកូវីដ-១៩នាំចូល ឬក៏ករណីពាក់ព័ន្ធដោយផ្ទាល់នឹងករណីនាំចូលសរុបចំនួន១៥១ករណី។ នៅមិនទាន់មានសញ្ញានៃការឆ្លងទៅសហគមន៍នៅឡើយទេ។ ករណីវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ៣៥ ត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកនៅក្នុងមន្ទីរពេទ្យ។ មិនមានសេចក្តីរាយការណ៍អំពីចង្កោមពាក់ព័ន្ធនឹងជំងឺផ្លូវដង្ហើមដែលមិនបានធ្វើរោគវិនិច្ឆ័យឃើញតាមរយៈបណ្តាញទូរស័ព្ទបន្ទាន់នោះទេ។ របាយការណ៍អំពីករណីជំងឺស្រដៀងផ្តាសាយ និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរនៅក្នុងខែកក្កដា មានកម្រិតទាបជាងកម្រិតដែលយើងបានរំពឹងទុក ដែលកម្រិតនេះមិនខុសពីកម្រិតនៅតំបន់ផ្សេងៗទៀតនៅទូទាំងពិភពលោកនោះទេ។ មនុស្សចំនួន ៦៣.៧៨៥នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិជ្ជាធ្វើតេស្តបែប PCR (Polymerase chain reaction, PCR) ជាមួយនឹងអត្រាវិជ្ជមានចំនួន ០,៤២ភាគរយ។ ការធ្វើតេស្តសរុបត្រឹមថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ មានចំនួន ៨០.៣៧៩ តេស្ត ដែលក្នុងនោះមានតេស្តទៅលើសំណាកបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (influenza-like illness, ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (severe acute respiratory infections, SARI) ចំនួន២.៣៨៩ ករណី។ ការតេស្តសំណាកចំនួន ២.៣៨៩ ទទួលបានលទ្ធផលអវិជ្ជមានវីរុសកូវីដ-១៩។

| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | ករណីសង្គ្រោះបន្ទាន់ |
|---|---|---|---|---|
| | 3,948<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 22<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(១០០ភាគរយ-៧ថ្ងៃ) | 0<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០ភាគរយ-៧ថ្ងៃ) | 0<br>ករណីសង្គ្រោះបន្ទាន់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០ភាគរយ-៧ថ្ងៃ) |
| | 80,379<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 273<br>ករណីសរុប | 0<br>ករណីស្លាប់សរុប | 0<br>ករណីសង្គ្រោះបង្ហាន់សរុប |



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧

១៧ សីហា ឆ្នាំ២០២០

របាយការណ៍គិតត្រឹមថ្ងៃទី១៧ សីហា ឆ្នាំ២០២០ ម៉ោង១០:00នាទីព្រឹក

**100%** ចំនួនករណីនាំចូលពីបរទេសក្នុងពេល២៨ថ្ងៃចុងក្រោយ(១០២)

**0%** ចំនួនករណីក្នុងរយៈពេល២៨ចុងក្រោយដែលគ្មានព័ត៌មានពាក់ព័ន្ធ (0)

**0** ចង្កោមសកម្ម

**0** ចង្កោមសកម្មដោយបានឆ្លងលើសបីតំណ

### ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩

**0** ចំនួនករណីបុគ្គលិកថែទាំសុខភាពដែលត្រូវបានរាយការណ៍កាលពីសប្តាហ៍កន្លងមក

**27** ចំនួនមន្ទីរពេទ្យដែលទទួលអ្នកជំងឺកូវីដ-១៩ឲ្យសម្រាកព្យាបាល

**13,667** ចំនួនគ្រែមន្ទីរពេទ្យរដ្ឋសរុប

**17** ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩

## អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ចំនួនករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍បែងចែកតាមស្ថានភាពនៃការឆ្លង និងកាលបរិច្ឆេទនៃលទ្ធផលតេស្តវិជ្ជមាន






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី១. តារាងនៃករណីឈឺសរុប និងថ្មី (ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ) និងករណីស្លាប់ បែងចែកតាមអាយុ និងភេទ**

| ក្រុមនៃអាយុ | ស្រី | | ប្រុស | | សរុប |
|---|---|---|---|---|---|
| | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ |
| 0-9 | **1(0)** | **0(0)** | **3(0)** | **0(0)** | **4(0)** |
| 10-19 | **1(1)** | **0(0)** | **3(0)** | **0(0)** | **4(1)** |
| 20-29 | **10(2)** | **0(0)** | **101(11)** | **0(0)** | **111(13)** |
| 30-39 | **9(0)** | **0(0)** | **49(6)** | **0(0)** | **58(6)** |
| 40-49 | **6(1)** | **0(0)** | **18(0)** | **0(0)** | **24(1)** |
| 50-59 | **9(1)** | **0(0)** | **15(0)** | **0(0)** | **24(1)** |
| 60-69 | **15(0)** | **0(0)** | **27(0)** | **0(0)** | **42(0)** |
| 70-79 | **2(0)** | **0(0)** | **4(0)** | **0(0)** | **6(0)** |
| 80-89 | **0(0)** | **0(0)** | **0(0)** | **0(0)** | **0(0)** |
| 90+ | **0(0)** | **0(0)** | **0(0)** | **0(0)** | **0(0)** |
| សរុប | **53(5)** | **0(0)** | **220(17)** | **0(0)** | **273(22)** |

**ក្រាហ្វិកទី២. ចំនួនសមាមាត្រនៃករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមក្រុមអាយុ និងសញ្ជាតិ (ចំនួន ២៧៣នាក់)**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៣. ចំនួនករណីជំងឺស្រដៀងផ្ដាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្ដាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្ដាហ៍ ឆ្នាំ២០២០ និងពីឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៩**




**ក្រាហ្វិកទី៤. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្ដាហ៍ ឆ្នាំ២០២០ និងពីឆ្នាំ២០១៧ ដល់២០១៩**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អភិក្រមយុទ្ធសាស្ត្រ

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មាធិការអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាមួយនឹងរដ្ឋលេខាធិការ
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ដែលដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩ថ្នាក់រាជនានី-ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះបាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រិត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩ វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។

## អាទិភាពសំខាន់ៗ

- នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសុខាភិបាល កំពុងរៀបចំបង្កើតយុទ្ធសាស្ត្រថែទាំសុខភាពបឋមសម្រាប់ជំងឺកូវីដ-១៩។ ឯកសារនេះ នឹងដាក់បញ្ចូលតួនាទី និងភារកិច្ចនានារបស់មណ្ឌលសុខភាពនៅក្នុងសេណារីយ៉ូមួយដែលអាចកើតមាននូវការឆ្លងជំងឺកូវីដ-១៩ទៅក្នុងសហគមន៍ ក៏ដូចជាគោលការណ៍គ្រប់គ្រងគ្លីនិក និងការបង្ការ និងត្រួតពិនិត្យការឆ្លងរោគ
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រពង្រីកមន្ទីរពិសោធន៍ ដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩។
- ការពង្រឹងការធ្វើចត្តាឡីស័កនៅតាមមូលដ្ឋានថែទាំសុខភាព ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ ដោយបង្កើតជាឧបករណ៍ជំនួយការងារសាមញ្ញៗសម្រាប់បុគ្គលិកនៅមូលដ្ឋានថែទាំសុខភាព។
- ការពង្រីកសមត្ថភាពធ្វើតេស្តរកកូវីដ-១៩ នៅមន្ទីរពិសោធន៍។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

### អភិក្រមយុទ្ធសាស្រ្តសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- *យុទ្ធសាស្រ្តសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្រ្តធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ យុទ្ធសាស្រ្តតាមដានជំងឺ កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់ នៅតាមតំបន់ដែលប្រឈមខ្ពស់ ឬតំបន់ដែលមានករណីវីរុសកូវីដ-១៩ ច្រើន (Hot-spot surveillance strategies) ក៏ដូចការធ្វើតេស្តទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations)។

- *ការទំនាក់ទំនង និងផ្សព្វផ្សាយពីហានិភ័យ និងការចូលរួមរបស់សហគមន៍*

យុទ្ធសាស្រ្តតាមដានជំងឺនៅកម្រិតមូលដ្ឋាន ត្រូវបានបង្កើតឡើង និងដាក់សាកល្បងស្រាវជ្រាវរកករណីវិជ្ជមានវីរុសកូវីដ-១៩ នៅតាមមណ្ឌលសុខភាព ហើយនិងនៅតាមសហគមន៍។ ក្រសួងមហាផ្ទៃកំពុងតែចូលរួមពង្រឹងការត្រួតពិនិត្យការធ្វើចត្តាឡីស័កដោយការរំលឹក និងពិន័យសម្រាប់បុគ្គលដែលមិនគោរពតាមគោលការណ៍ណែនាំ។

យុទ្ធសាស្រ្តជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានព្រៀងរួចរាល់ហើយ។ ក្រសួងសុខាភិបាល បានបង្កើតផែនការត្រួតពិនិត្យពីការទំនាក់ទំនងនិងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍ និងបានអនុវត្តតាំងតែពីខែឧសភា ឆ្នាំ២០២០មករហូតមកដល់ខែកក្កដា ឆ្នាំ២០២០ សម្រាប់បុគ្គលិកថែទាំសុខាភិបាលនៅក្នុងខេត្តចំនួន១២។

- *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្រ្ត (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*

## បទពិសោធន៍ល្អៗ និងមេរៀនដែលបានរៀន

### កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
    - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្រ្តី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្រ្តីសុខាភិបាល។
    - ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
    - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
    - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងតាមរយៈសេចក្តីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - សម្ភារទំនាក់ទំនងសម្រាប់ទស្សនិកជន និងអ្នកស្តាប់គោលដៅ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមដែលមានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) និងកម្មកររោងចក្រ។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្តប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបិត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (Non-Pharmaceutical Interventions, NPIs)

### **សេចក្តីពណ៌នាអំពីអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ** (Narrative Non-Pharmaceutical Interventions)

អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រទ្រង់ទ្រាយធំ ដែលត្រូវបានប្រកាសនៅថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០ រួមមានការបិទគ្រឹះស្ថានសិក្សាទូទាំងប្រទេស ហើយជំនួសវិញដោយដំណើរការសិក្សាតាមអនឡាញ។

នៅថ្ងៃទី ២១ ខែកក្កដា ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសេចក្តីប្រកាសមួយ អនុញ្ញាតឲ្យសាលារៀនឯកជនស្តង់ដារសុវត្ថិភាពខ្ពស់ ចំនួន២០ នៅភ្នំពេញ សៀមរាប និងបាត់ដំបង បើកដំណើរការឡើងវិញចាប់ពីខែសីហា នៅក្នុងដំណាក់កាលទី១នៃផែនការបើកសាលារៀនឡើងវិញដែលមានបីដំណាក់កាល។ កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចុះហត្ថលេខាដាក់ឲ្យប្រើគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទកូវីដ-១៩។ ក្រសួងអប់រំយុវជននិងកីឡា និងសាលារៀនមួយចំនួន ក៏បានចុះហត្ថលេខលើអនុសារណៈនៃការយោគយល់គ្នាមួយដើម្បីអនុញ្ញាតឲ្យបើកដំណើរការសាលារៀនឡើងវិញ។ កាលពីពាក់កណ្តាលខែសីហា រាជរដ្ឋាភិបាលបានសម្រេចផ្លាស់ប្តូរដំណាក់កាលទីពីរនៃផែនការបើកសាលារៀនឡើងវិញ ដែលនេះមានន័យថា ការបើកសាលារៀនឡើងវិញសម្រាប់សិស្សថ្នាក់ទី៩ និងថ្នាក់ទី១២ នឹងប្រព្រឹត្តទៅនៅខែកញ្ញា ឆ្នាំ២០២០។

នៅថ្ងៃទី ១៥ កក្កដា ក្រសួងមហាផ្ទៃបានរៀបចំកិច្ចប្រជុំជាន់ខ្ពស់រវាងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិនៅកម្ពុជាស្តីពីកម្មវិធីរួមគ្នាដើម្បីគាំទ្រជនទេសន្តប្រវេសន៍ (ពលករចំណាកស្រុក) ដែលវិលត្រឡប់ក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩។ កិច្ចសហការ កំពុងតែបន្តរវាងរាជរដ្ឋាភិបាល និងដៃគូអង្គការសហប្រជាជាតិ ដើម្បីរៀបចំផែនការការងារសម្រាប់បង្កើតមូលនិធិពហុភាគីដើម្បីដោះស្រាយបញ្ហាជំងឺកូវីដ-១៩។

ខារ៉ាអូខេ និងក្លឹបកំសាន្ត ត្រូវបានបិទដំណើរការនៅថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០២០។ នៅថ្ងៃទី៧ ខែកក្កដា សាលារាជធានីភ្នំពេញ បានប្រកាសថាខារ៉ាអូខេ និងក្លឹបកំសាន្តនានា អាចបើកដំណើរការឡើងវិញបាន ទាល់តែកែច្នៃខារ៉ាអូខេ និងក្លឹបកំសាន្តទាំងនោះ អោយទៅជាភោជនីយដ្ឋានវិញ ហើយនិងទទួលបានការអនុញ្ញាតពីសាលារាជធានីទើបអាចបើកដំណើរការបាន។ ទីតាំងទាំងនោះ ត្រូវតែគោរពតាមវិធានការនានាដែលចេញដោយក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ដូចជារក្សាគម្លាតសុវិត្ថិភាព រក្សាទីតាំងអោយមានខ្យល់អាកាសចេញចូល និងវិធានការប្រុងប្រយ័ត្នផ្សេងៗទៀត។

កាលពីថ្ងៃទី០៦ ខែសីហាឆ្នាំ២០២០ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រកាសថារាជរដ្ឋាភិបាលនឹងអនុញ្ញាតឲ្យបើកដំណើរការរោងកុនឡើងវិញ តែតម្រូវឲ្យរោងកុនអនុវត្តនូវគោលការណ៍ប្រតិបត្តិស្តង់ដារ និងវិធានការការពារសុវត្ថិភាពដទៃទៀតដែលមានស្រាប់និងដែលក្រសួងសុខាភិបាល និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានដាក់ចេញ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ដើម្បីកាត់បន្ថយការនាំចូលករណីកូវីដ-១៩ពីបរទេស ការមកដល់នៃអ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិពីប្រទេសជាច្រើនដែលកំពុងតែយាយីធ្ងន់ធ្ងរដោយបញ្ហាកូវីដ-១៩ ត្រូវបានហាមឃាត់ចាប់តាំងពីខែមិនាមក។ ការលើកបម្រាមនេះវិញកាលពីថ្ងៃ ២០ ខែឧសភា ត្រូវបានភ្ជាប់មកជាមួយនូវលក្ខខណ្ឌតម្រូវយ៉ាងតឹងរឹងសម្រាប់ជនបរទេសដែលមិនមែនជាទូត ចូលមកកម្ពុជា ដូចជាតម្រូវឲ្យមានលិខិតបញ្ជាក់សុខភាពថាមិនមានវិជ្ជមានវីរុសកូវីដ-១៩ ការធានារ៉ាប់រងសុខភាព ការធ្វើតេស្តពេលធ្វើដំណើរមកដល់ ការដាក់ឲ្យធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ និងការធ្វើតេស្តម្តងទៀតនៅថ្ងៃទី១៣។

កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានប្រកាសនូវការកែសម្រួលវិធានការសុខាភិបាលសម្រាប់អនុវត្តចំពោះមន្ត្រីការទូត និងអង្គការអន្តរជាតិដែលកាន់ទិដ្ឋាការការទូតប្រភេទ A និងទិដ្ឋាការផ្លូវការប្រភេទ B។ មន្ត្រីការទូត និងអង្គការអន្តរជាតិ តម្រូវឲ្យមានវិញ្ញាបនបត្របញ្ជាក់សុខភាព ចេញដោយអាជ្ញាធរសុខាភិបាលដែលទទួលស្គាល់ដោយប្រទេសសាមីបញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ រយៈពេល៧២ម៉ោងមុនពេលចេញដំណើរ ហើយសំណាក់យកនៅទីតាំងពិសេសក្នុងស្ថានីយមកដល់របស់អ្នកដំណើរតែម្តង។

កាលពីថ្ងៃទី ២៦ ខែកក្កដា រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្អាកជាបណ្តោះអាសន្ននូវជើងហោះហើរពីប្រទេសម៉ាឡេស៊ី និងប្រទេសឥណ្ឌូនេស៊ីចាប់ពីថ្ងៃទី០១ ខែសីហាតទៅ។ វិធានការទាំងនេះ ឆ្លើយតបទៅនឹងចំនួនកើនឡើងនៃករណីវិជ្ជមានវីរុសកូវីដ-១៩ នាំចូលមកពីប្រទេសទាំងពីរនេះនៅក្នុងខែមិថុនា និងខែកក្កដា។ ក្រោយមកទៀតមានបម្រាមជើងហោះហើរមកពីប្រទេសហ្វីលីពីនដែលបានចូលជាធរមាននៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។

វិធានការមួយចំនួនក៏ត្រូវបានដាក់ចេញ មុននឹងការចូលមកដល់នៃពិធីចូលឆ្នាំខ្មែរផងដែរ ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ទៅសហគមន៍ណាមួយ។ ពិធីចូលឆ្នាំខ្មែរដែលជាធម្មតាត្រូវប្រារព្ធនៅខែមេសា ត្រូវបានលើកពេលមកប្រារព្ធនៅថ្ងៃទី១៧ ដល់ថ្ងៃ២១ ខែសីហាជំនួសវិញ ហើយពិធីបុណ្យអុំទូករយៈពេលបីថ្ងៃនៅខែតុលាត្រូវបានលុបចោល។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈ: មិនមែនវេជ្ជសាស្ត្រ(NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬ តម្រូវឲ្យ (Recommended or Required) | លើកសម្រាប់ វិស័យ/ផ្នែកខ្លះ: (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | មិនមានទេ (None) | | | | |
| បិទសាលារៀន (School Closure) | ១៦ មិនា | ផែនការបើកសាលាឯកជនចំនួន២០ដែលអាចអនុវត្តវិធានការសុខភាពសាធារណៈចាប់ពីខែសីហាឡើងវិញ និងផែនការបើកសាលារៀនសម្រាប់សិស្សថ្នាក់ទី៩ និងទី១២នៅទូទាំងប្រទេសឡើងវិញកំពុងដំណើរការ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា | ១៥ មិថុនា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ: (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា | មិនមានទេ (None) | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | ទេ (No) | លើកទាំងស្រុង (Yes) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា | ១១ សីហា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់ទេ (No) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៥. ពេលវេលាអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ រួមបញ្ចូលជាមួយនឹងខ្សែកោងនៃការរាតត្បាតដោយជំងឺកូវីដ-១៩ (NPIs timeline combined with epidemic curve)**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។